01318680

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 08 / 2016
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/449

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ពុធ ទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦

## សវនាការលើអង្គសេចក្ដី - ថ្ងៃ ៤៣០

រៀបចំដោយ៖ លោកស្រី សែ គុលវុឌ្ឍី និង លោក Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួម |
| --- |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William SMITH, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លឺវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ, |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី ទី ស្រីនណា, លោកស្រី ជេត វណ្ណលី, លោក ឡោ ជុនធី, លោក វ៉េន ពៅ |

| |
|---|
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ សាក្សី 2-TCW-1005 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក អ៊ុច អរុណ, លោក ឡុញ ង៉ែត, លោកស្រី ពេជ្រ ចរិយា, កញ្ញា យស សិរីរ័ត្ន, កញ្ញា សុក សុភក័មណីការ, លោក Georgina QUINTON SMITH |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៦.០៣ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៨ | បញ្ចប់ម៉ោង៖ ១០.៣៩ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.២៨ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១៤ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៥ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៥ | ០៩.០៧ |
| ការបន្តតាំងសំណួរទៅសាក្សី (2-TCW-1005) | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ០៩.០៧<br>១០.៤៨<br>១៣.៣១<br>១៤.១៣ | ១០.១៨<br>១១.២៨<br>១៣.៥៣<br>១៦.០២ |
| ការបញ្ជាក់របស់មេធាវីការពារក្ដី ខៀវ សំផន ទៅលើការដាក់បង្ហាញឯកសារសារថ្មីៗពាក់ព័ន្ធនឹងកំណត់ហេតុស្ដាប់ចម្លើយពីក្នុងសំណុំរឿង ០០៣ និង ០០៤ | មេធាវីការពារក្ដី ខៀវ សំផន | ១០.៣៩ | ១០.៤៨ |
| សេចក្ដីសម្រេចផ្ទាល់មាត់ទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដី នួន ជា សុំតាំង | មេធាវីការពារក្ដី នួន ជា | ១៣.៥៣ | ១៤.១៣ |

| | | | |
|---|---|---|---|
| សំណួរទៅអ្នកជំនាញ ហង់រី ឡូកា 2-TCE-90 នៅថ្ងៃចន្ទ ទី ០១ ខែ សីហា ២០១៦ | | | |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែ លោកស្រី Marie GUIRAUD អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការបន្តតាំងសំណួរទៅសាក្សី 2-TCW-1005</u>**

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួន និងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់សាក្សី បន្ទាប់មក សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅសាក្សី 2-TCW-1005។

**<u>ការបញ្ជាក់របស់មេធាវីការពារក្តី ខៀវ សំផន ទៅលើការដាក់បង្ហាញឯកសារសារថ្មីៗពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយពីក្នុងសំណុំរឿង ០០៣ និង ០០៤</u>**

មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបញ្ជាក់ទៅលើឯកសារដាក់បង្ហាញថ្មីៗនេះទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយដែលទទួលបានពីការស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយសារតែភាពចាំបាច់នៃការទទួលបានកំណត់ហេតុស្តាប់ចម្លើយនោះឱ្យបានមុនពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី។

**<u>សេចក្តីសម្រេចផ្ទាល់មាត់ទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី នួន ជា សុំតាំងសំណួរទៅអ្នកជំនាញ ហង់រី ឡូកា 2-TCE-90 នៅថ្ងៃចន្ទ ទី ០១ ខែ សីហា ២០១៦</u>**

មេធាវីការពារក្តី នួន ជា ស្នើសុំការអនុញ្ញាតក្នុងការតាំងសំណួរទៅអ្នកជំនាញ ហង់រី ឡូកា នៅថ្ងៃ ចន្ទ ទី ០១ ខែ សីហា ឆ្នាំ ២០១៦ ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យមើលឯកសារសម្រង់ពីសៀវភៅរបស់អ្នកជំនាញ ដែលនឹងត្រូវប្រើប្រាស់នៅពេលសវនាការដោយសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំ និងបានចេញដីកាកំណត់កាលបរិច្ឆេទដែលបានកែសម្រួលសម្រាប់ការស្តាប់សក្ខី

កម្មអ្នកជំនាញរូបនេះ។ អង្គជំនុំជម្រះក៏បានស្នើសុំឱ្យសហព្រះរាជអាជ្ញាផ្តល់ការជូនដំណឹងជាមុនពីសម្រង់អត្ថបទនៃសៀវភៅរបស់អ្នកជំនាញ ដែលសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់នៅក្នុងពេលសវនាការ។

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10604 | / | / 01222328-01222936 / | Annex 2: OCIJ S-21 Prisoners List 31 March 2016 | P | / | / | / |
| E3/765 | / | 00376472-00376507 00539976-00540007 00540008-00540037 | Revolutionary Youth Number 10 October 1978 | P | / | 00539994 | / |
| E3/10628 | / | 01127703-01127714 01142598-01142611 / | Written Record of Interview of [name remains confidential] | C | 01127710 | 01142606 | / |
| E3/10639 | / | 01089446-01089489 01098403-01098427 / | Written Record of Interview of [name remains confidential] | C | 01089487 | 01098426 | / |
| E3/10622 | / | 01136699-01136731 01170582-01170601 / | Written Record of Interview of [Witness 2-TCW-1005] | C | 01136714 01136717 | 01170591 01170593 | / |
| E3/9647 | / | 00975710-00975759 00992978-00993009 and 01212263-01212339 00996550-00996599 | DC-Cam Interview of [Witness 2-TCW-1005] | C | 00975723 00975746 00975742 | 01212283 01212318 01212312 | 00996564 00996586 00996581 |

| **ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖** |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៧)<br>• សម្រេចឱ្យមានការកែតម្រូវកាលវិភាគសវនាការទាក់ទងនឹងការស្តាប់សក្ខីកម្មអ្នកជំនាញ ហង់រី ឡូកា។ អង្គជំនុំជម្រះនឹងតាំងសំណួរទៅអ្នកជំនាញនៅថ្ងៃ ព្រហស្បតិ៍ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតាំងសំណួរទៅអ្នកជំនាញនៅថ្ងៃ សុក្រ ទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ ហើយមេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន នឹងចាប់ផ្តើមតាំងសំណួរទៅអ្នកជំនាញនៅថ្ងៃ ចន្ទ ទី ០១ ខែ សីហា ឆ្នាំ ២០១៦។ (១៥.១១)<br>• ស្នើឱ្យសហព្រះរាជអាជ្ញាផ្តល់ការបញ្ជាក់ទៅភាគីពាក់ព័ន្ធនឹងអត្ថបទសម្រង់ណាខ្លះនៃសៀវភៅរបស់អ្នកជំនាញ ហង់រី ឡូកា ដែលសហព្រះរាជអាជ្ញានឹងប្រើប្រាស់នៅពេលតាំងសំណួរទៅអ្នកជំនាញ។<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ។ (១៦.០២) |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ គុណវឌ្ឍនា លោក Matteo CRIPPA